**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែក និងកាមរោគ**

## វគ្គបណ្តុះបណ្តាលដល់គ្រូពេទ្យ និងក្រុមការងារ ART ស្តីពី
## « ការពិនិត្យស្រាវជ្រាវ និងគ្រប់គ្រងគ្លីនិក ជំងឺមិនឆ្លងកម្រិតស្រាល និងស្ថានភាពជំងឺអេដស៍ធ្ងន់ សម្រាប់ការផ្តល់សេវាថែទាំ ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ »

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូពេទ្យ និងក្រុមការងារ ART ស្តីពី « ការពិនិត្យស្រាវជ្រាវ និងគ្រប់គ្រងគ្លីនិក ជំងឺមិនឆ្លងកម្រិតស្រាល និងស្ថានភាពជំងឺអេដស៍ធ្ងន់ សម្រាប់ការផ្តល់សេវាថែទាំ ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ » ដែលប្រព្រឹត្តទៅនៅថ្ងៃទី៤ ដល់ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ នៅមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តតាកែវ ដោយមានការគាំទ្រថវិកា និងបច្ចេកទេស ដោយគម្រោង US-CDC Cambodia។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីបង្កើនចំណេះដឹង និងសមត្ថភាពបន្ថែមរបស់សិក្ខាកាមអំពី គោលការណ៍ណែនាំជាតិទាក់ទងនឹងការពិនិត្យស្រាវជ្រាវ និងគ្រប់គ្រងគ្លីនិក ជំងឺមិនឆ្លងកម្រិតស្រាល និងស្ថានភាពជំងឺអេដស៍ធ្ងន់ សម្រាប់ការផ្តល់សេវាថែទាំព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។




វគ្គបណ្តុះបណ្តាលនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកឱសថការី ផាន់ វ៉ាន់** ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តតាកែវ **លោកវេជ្ជ. លី វណ្ណធី** អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺមិនឆ្លងសហរដ្ឋអាមេរិក និង**លោកវេជ្ជ. ប្រាក់ ណារុំ** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលបានផ្តល់មតិសំណេះសំណាល ចំណាប់អារម្មណ៍ និងប្រកាសបើកវគ្គបណ្តុះបណ្តាល។

សិក្ខាកាមអញ្ជើញមកពី មន្ទីរពេទ្យបង្អែកខេត្តកែប មន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង មន្ទីរពេទ្យបង្អែករមាសហែក មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ មន្ទីរពេទ្យបង្អែកបារាយណ៍-សន្ទុក មន្ទីរពេទ្យបង្អែកជ័យជំនះ មន្ទីរពេទ្យបង្អែកកោះធំ មន្ទីរសុខាភិបាលខេត្តតាកែវ មន្ទីរពេទ្យបង្អែកខេត្តតាកែវ មន្ទីរពេទ្យបង្អែកអង្គរកា មន្ទីរពេទ្យបង្អែកព្រែកប្បាស និងមន្ទីរពេទ្យបង្អែកគិរីវង់ ជាប្រធានក្រុម ឬជាគ្រូពេទ្យនៃសេវា ART និងអង្គការដៃ ដូចជា PC AHF និងMHC និងគ្រូសម្របសម្រួល NCHADS សរុបចំនួន ៣៦ នាក់។ គ្រូសម្របសម្រួលបានធ្វើបទបង្ហាញ ដូចជា៖ បច្ចុប្បន្នភាព និងលទ្ធផលនៃការងារថែទាំព្យាបាលគិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៥, បច្ចុប្បន្នភាព/ការកែសម្រួលគោលការណ៍ណែនាំជាតិ និងសេចក្តីណែនាំទាក់ទងនឹងការគ្រប់គ្រងគ្លីនិកចំពោះមនុស្សពេញវ័យ និងកុមារ ដែលផ្តោតលើ TAF NCD និង AHD។



